ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខ:......៤៤៥/១៧ គ.ជ.ប.ជ

# របាយការណ៍បូកសរុបសកម្មភាព
# និងលទ្ធផលការងារបង្ការ-ទប់ស្កាត់ និងបង្ក្រាបអំពើជួញដូរមនុស្ស
# និងអំពើធ្វើអាជីវកម្មផ្លូវភេទ ប្រចាំខែតុលា និងទិសដៅខែវិច្ឆិកា ឆ្នាំ២០១៧

## I. ស្ថានភាពទូទៅ

ក្នុងខែតុលា ឆ្នាំ២០១៧ ស្ថានភាពបទល្មើសជួញដូរមនុស្ស ត្រូវបានរកឃើញ និងបង្ក្រាបជាបន្តបន្ទាប់គួរឲ្យកត់សម្គាល់។ មិនតែប៉ុណ្ណោះ ក៏មានលេចចេញនូវបទល្មើសជួញដូរសរីរាង្គ និងបទអន្តរការីនៃអំពើពពោះជំនួស ដើម្បីនាំយកទារកចេញទៅក្រៅប្រទេស ដែលជាសញ្ញាណថ្មីពាក់ព័ន្ធនឹងបទល្មើសរត់ពន្ធ ឬជួញដូរទារកឆ្លងដែន។ រាជរដ្ឋាភិបាល បានយកចិត្តទុកដាក់ ដោះស្រាយ និងបង្ការ ទប់ស្កាត់ ជាបន្ទាន់ដោយចាប់ផ្តើមកសាងច្បាប់ដើម្បីគ្រប់គ្រងសកម្មភាពពពោះជំនួសឲ្យបានឆាប់។

ដោយឡែកការធ្វើចំណាកស្រុកឆ្លងដែន ឬទេសន្តរប្រវេសន៍ ក៏មានស្ថានភាពមិនប្រក្រតី ដោយមានប្រជាពលរដ្ឋចាកចេញទៅធ្វើការនៅប្រទេសថៃហូតដល់ជាងមួយលាននាក់ ទាំងស្របច្បាប់ ទាំងមិនមានឯកសារច្បាប់។ ថ្មីៗនេះ រាជរដ្ឋាភិបាលថៃ បានចេញគោលការណ៍រឹតបន្តឹងពលករទេសន្តប្រវេសន៍ ដែលរស់នៅ និងធ្វើការខុសច្បាប់ក្នុងប្រទេសថៃ។ ដើម្បី ជាដំណោះស្រាយ រដ្ឋាភិបាលថៃបានទុករយៈពេល៦ខែ ពីខែមិថុនា ដល់ចុងខែធ្នូ ឆ្នាំ២០១៧ ដើម្បីឲ្យពលកររៀបចំបំពេញបែបបទឯកសារស្របច្បាប់ ជាពិសេសលិខិតឆ្លងដែន ឲ្យទាន់ពេលវេលា ពុំនោះទេពលករទាំងនោះនឹងត្រូវបញ្ជូនត្រឡប់មកប្រទេសដើមវិញ។ រាជរដ្ឋាភិបាលកម្ពុជា បានបញ្ជូនក្រុមការងារផ្តល់ភាពស្របច្បាប់ ជូនពលករ ជិតបួនរយនាក់ ដើម្បីផ្តល់លិខិតឆ្លងដែន និងសម្រួលការបំពេញបែបបទស្របច្បាប់ នៅទីក្រុងបាងកក ខេត្តរ៉ៃយ៉ង ឆាកធឹងសាវ និងប៉ាធុមថានី ដើម្បីពន្លឿនការទទួលបានភាពស្របច្បាប់ដល់ពលករកម្ពុជា។ ទោះបីជាយ៉ាងនេះក្តី ក៏នៅមានពលករប្រមាណជាជាង៣០ម៉ឺននាក់ទៀត នៅមិនទាន់មានឯកសារស្របច្បាប់នៅឡើយក្នុងប្រទេសថៃ និយាយដោយឡែក និងជារួមនៅតាមបណ្តាប្រទេសមួយចំនួនទៀត។

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានអគ្គលេខាធិការដ្ឋាន **គ.ជ.ប.ជ** ជាសេនាធិការ បានបន្តសម្របសម្រួល ពង្រឹងកិច្ចសហការជាមួយដៃគូជាតិ និងអន្តរជាតិពាក់ព័ន្ធ ប្រមូលផ្តុំកម្លាំងចូលរួមរបស់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាព រាជធានី-ខេត្ត ដើម្បីបង្កើនកិច្ចខិតខំប្រឹងប្រែងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរកដំណោះស្រាយបញ្ហាប្រឈមនានា។ របាយការណ៍ដែលអគ្គលេខាធិការដ្ឋានប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សទទួលបានគឺ ៖

- សម្រាប់បណ្តាក្រសួង ស្ថាប័ន ថ្នាក់ជាតិ មានអគ្គស្នងការដ្ឋាននគរបាលជាតិ(ក្រុមការងារអនុវត្តន៍ច្បាប់) និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (ក្រុមការពារជនរងគ្រោះ) ចំនួន០២ ដែលបានផ្តល់របាយការណ៍។ ដោយឡែកក្រសួង ស្ថាប័នចំនួន០៤ ដែលជាយន្តការសម្រប

សម្រួលការងារដឹកនាំ និងអនុវត្ត ដើម្បីជានាឲ្យមានកិច្ចសហការរវាងក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀត មិនទាន់បានផ្ញើរបាយការណ៍។

- សម្រាប់បណ្តាស្ថាប័ន ថ្នាក់ក្រោមជាតិ មានលេខាធិការដ្ឋានរាជធានី-ខេត្តចំនួន២០ បានផ្តល់របាយការណ៍ ចំណែកចំនួន០៥ខេត្ត គឺកំពត ប៉ៃលិន សៀមរាប ត្បូងឃ្មុំ និងកំពង់ស្ពឺ នៅមិនទាន់បានផ្ញើរបាយការណ៍។

ជាលទ្ធផល ដែលសម្រេចបានក្នុងខែតុលា ឆ្នាំ២០១៧នេះ មានដូចខាងក្រោម៖

## II. ការអនុវត្តតាមផែនការយុទ្ធសាស្ត្រសកម្មភាពជាតិ (២០១៤-២០១៨)

### ក. ពង្រឹងការអនុវត្តច្បាប់ គោលនយោបាយ និងលើកកម្ពស់សមាប្រតិបត្តិការ

#### ក.១ ការងារច្បាប់ និងគោលនយោបាយជាតិ

##### ក.១.១-កិច្ចការច្បាប់

❖ **លិខិតបទដ្ឋានដែលកំពុងរៀបចំ**

- សេចក្តីព្រាងច្បាប់ ស្តីពី "**ការគ្រប់គ្រងការពពោះជំនួស**" (ក្រសួងកិច្ចការនារី)
- សេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្ត "**សម្រាប់អនុវត្តល័ក្ខខ័ណ្ឌការងារកម្មករការងារផ្ទះ**" (ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ)
- សេចក្តីព្រាងគោលនយោបាយ ស្តីពី "**កិច្ចការការពារកុមារតាមសាលារៀន**" (ក្រសួងអប់រំ យុវជន និងកីឡា)
- **ក្រសួងយុត្តិធម៌** បានរៀបចំសេចក្តីព្រាងសន្ធិសញ្ញា និងកំពុងពិភាក្សារួមមាន៖
  - សេចក្តីព្រាងសន្ធិសញ្ញា ស្តីពី "**ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ**" (**ច្បាប់ជាតិ**)
  - សេចក្តីព្រាងសន្ធិសញ្ញា ស្តីពី "**ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ**" រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតឡាវ សាធារណរដ្ឋកូរ៉េ រដ្ឋាភិបាលបារាំង និងរដ្ឋាភិបាលរុស្ស៊ី។
  - សេចក្តីព្រាងសន្ធិសញ្ញា ស្តីពី "**បត្យាប័ន**" រវាងព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលឥណ្ឌា។
  - សេចក្តីព្រាង កិច្ចព្រមព្រៀង ស្តីពី "**បញ្ជូនទណ្ឌិត**" រវាងព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលអង់គ្លេស រដ្ឋាភិបាលប៉េរូ សាធារណរដ្ឋប្រជាមានិតឡាវ និងរដ្ឋាភិបាលរុស្ស៊ី និង
  - សេចក្តីព្រាងច្បាប់ ស្តីពី "**ការប្រឆាំងអំពើគេចពន្ធមនុស្ស**"។

##### ក.១.២-លិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធ

- **ក្រសួងយុត្តិធម៌**បានអនុម័ត បញ្ចូលឯកសារបណ្តុះបណ្តាល ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរបស់អាស៊ានសម្រាប់ព្រះរាជអាជ្ញា និងតុលាការ ដើម្បីដាក់បញ្ចូលទៅក្នុងកម្មវិធីសិក្សារបស់រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ។

##### ក.១.៣-អនុស្សរណៈ

❖ **អនុស្សរណៈកំពុងរៀបចំ**

-**គណៈកម្មាធិការជាតិ គ.ជ.ប.ជ** ត្រៀមចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាជាមួយប្រទេសឥណ្ឌា ស្តីពី "**កិច្ចសហប្រតិបត្តិការបង្ការ ទប់ស្កាត់ និងបង្ក្រាបអំពើជួញដូរមនុស្ស**"។

-**ក្រសួងទេសចរណ៍** ត្រៀមចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីការអនុវត្តគម្រោងកុមារភាពជាមួយអង្គការ Friends International។ Sutha

## ខ.ការបង្ការទប់ស្កាត់

**ខ.១-កាត់បន្ថយភាពងាយរងគ្រោះដល់ជនមុខសញ្ញាងាយរងគ្រោះ៖**

ប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-ថៃ ចំនួន០៥ គឺប៉ុស្តិ៍ ច្រកប៉ោយប៉ែត ច្រកដូង ច្រកព្រំ ច្រកអូរស្មាច់ និងច្រកចាំ បានជួយសម្រួល និងផ្តល់ប័ណ្ណព្រំដែនកម្ពុជា-ថៃ ចំនួន២០.៨៣០ក្បាល ដល់ពលរដ្ឋខ្មែរដែលរស់នៅក្នុងខេត្តជាប់ព្រំដែន (*របាយការណ៍អគ្គនាយកដ្ឋានអន្តោប្រវេសន៍*)។

**ខ.២-ការអប់រំ ផ្សព្វផ្សាយតាមរយៈកិច្ចប្រជុំ វេទិកាសាធារណៈ**

ស្ថាប័នថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ អាជ្ញាធរ និងសមត្ថកិច្ចពាក់ព័ន្ធ សហការជាមួយអង្គការដៃគូ បានធ្វើការផ្សព្វផ្សាយ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងវេទិកាសាធារណៈនៃការអនុវត្តគោលនយោបាយ "**ភូមិ-ឃុំមានសុវត្ថិភាព**" ដល់អាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋបានចំនួន៤.៨៩៦លើក ដែលមានអ្នកចូលរួមសរុបចំនួន៤៤៧.៣០៩នាក់ (បើប្រៀបធៀបនឹងខែមុន មានចំនួនត្រឹមតែ ២៩០.២៤៣នាក់) កើនឡើង១៥៧.០៦៦នាក់ ស្មើនឹង៥៤.១១% ក្នុងនោះស្ត្រីមានចំនួន១៤២.៨៤៩នាក់។ (ឧបសម្ព័ន្ធទី១)

**ខ.៣-ការផ្សព្វផ្សាយតាមរយៈសម្ភារៈ និងតាមប្រព័ន្ធព័ត៌មាន**

- **ខេត្តបាត់ដំបង៖**
  - **មជ្ឈមណ្ឌលការងារ** ចែកខិត្តបណ្ណផ្សព្វផ្សាយសេវាការងារ និងអ្នកស្វែងរកការងារ បានចំនួន៩៣សន្លឹក។
  - **អង្គការសាម៉ារីតាន់** ចែកខិត្តប័ណ្ណផ្សព្វផ្សាយ ដល់ជនចំណាកស្រុកចំនួន២៧នាក់។
- **ខេត្តកោះកុង៖**
  - ផ្សព្វផ្សាយកម្មវិធីកិច្ចពិភាក្សា ស្តីពីជម្រើសដោយសុវត្ថិភាពតាមវិទ្យុសាគរកោះកុង ក្រោមប្រធានបទ លទ្ធផលនៃការជួញដូរមនុស្ស ការធ្វើចំណាកស្រុក និងការរំលោភបំពានផ្លូវភេទ សហការជាមួយអង្គការចាប់ដៃ សរុបចំនួន៣១លើក ក្នុងនោះរួមមាន៖
    - ការជួញដូរមនុស្ស ចំនួន១៤លើក
    - ការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងដោយប្រថុយប្រថាន ចំនួន១០លើក
    - ការរំលោភបំពានផ្លូវភេទលើកុមារ ចំនួន០៧លើក។

**ខ.៤-ទប់ស្កាត់ រារាំងតម្រូវការសេវាកម្ម ដែលទំនោរទៅរកការជួញដូរមនុស្ស**

ខ.៤.១-<u>វិធានការទប់ស្កាត់តាមជំនាញរបស់អគ្គស្នងការដ្ឋាននគរបាលជាតិ</u>

- **ខេត្តបន្ទាយមានជ័យ** កម្លាំងការិយាល័យជំនាញ ប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន សហការជាមួយ កម្លាំងអធិការដ្ឋាននគរបាលស្រុកអូរជ្រៅ ប៉ុស្តិ៍អូរបីជាន់ ធ្វើការទប់ស្កាត់ពលករចំណាកស្រុកខុសច្បាប់ទៅរកការងារ ធ្វើនៅប្រទេសថៃនៅចំណុច ភូមិជោគជ័យ ក្នុងភូមិសាស្ត្រឃុំអូរបីជាន់ ស្រុកអូរជ្រៅ ចំនួន០២លើក មនុស្សចំនួន២០នាក់ ស្រី១១នាក់។

ខ.៤.២-<u>**វិធានការបង្ការ ទប់ស្កាត់ ការជួញដូរមនុស្ស ក្នុងគោលដៅបម្រើសេវាកម្មផ្លូវភេទ៖**</u>

ក្នុងខែតុលា ឆ្នាំ២០១៧នេះ អគ្គស្នងការដ្ឋាននគរបាលជាតិ (របាយការណ៍ពីក្រុមការងារអនុវត្តន៍ច្បាប់) និងស្នងការរាជធានី-ខេត្ត បានសហការជាមួយស្ថាប័នពាក់ព័ន្ធ ដើម្បីធ្វើសកម្មភាពបង្ការទប់ស្កាត់តាមគោលដៅ ទទួលបានលទ្ធផលដូចខាងក្រោម ៖

- ស្រង់ស្ថិតិ ទិន្នន័យ និងធ្វើកិច្ចសន្យាហាមឃាត់ការប្រព្រឹត្តបទល្មើសសញ្ញាកម្ម និងផ្សព្វផ្សាយច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដល់ម្ចាស់អាជីវកម្ម និងស្ត្រី-បុរសធ្វើការក្នុងហាងម៉ាស្សា ខារ៉ាអូខេ បានចំនួន៤៩៦គោលដៅ មានមនុស្សចំនួន១.៩៧៨នាក់

(ស្រី១.៦៦៨នាក់) **កម្លាំងជំនាញអនុវត្ត នៃស្នងការដ្ឋាននគរបាលខេត្ត មាន៖** (តាកែវ ព្រះវិហារ កណ្ដាល កែប កំពត មណ្ឌលគិរី ស្ទឹងត្រែង រតនគិរី កោះកុង និងក្រចេះ)។

- គោលដៅសង្ស័យប្រព្រឹត្តបទល្មើសជួញដូរមនុស្ស និងការធ្វើអាជីកម្មផ្លូវភេទ ក្នុងនោះអំពើជួញដូរមនុស្ស ចំនួន០៩គោលដៅ និងអំពើធ្វើអាជីវកម្មផ្លូវភេទចំនួន៦៦គោលដៅ សរុបចំនួន**៧៥**គោលដៅ ទូទាំងរាជធានី-ខេត្ត។
- ការល្បាតឃ្លាំមើលគោលដៅសង្ស័យមានសកម្មភាពអាជីវកម្មផ្លូវភេទ ធ្វើបានចំនួន**២៧**លើក ក្នុងនោះ ខេត្តដែលអនុវត្តមាន៖ ស្វាយរៀង ព្រៃវែង កំពង់ស្ពឺ និងពោធិ៍សាត់។

**ខ.៥.គោលនយោបាយប្រឆាំងនឹងទេសន្តរប្រវេសន៍ខុសច្បាប់ និងគ្រោះថ្នាក់**

**ខ.៥.១. __វិធានការគ្រប់គ្រងបច្ចុប្បន្នភាពចំណាកស្រុក__**

- ***បច្ចុប្បន្នភាពស្ថិតិចំណាកស្រុក***

បច្ចុប្បន្នភាពទិន្នន័យពលករចំណាកស្រុកទៅក្រៅប្រទេស បានពិនិត្យឃើញថា នៅតែបន្តកើតមានឡើង ជាក់ស្ដែងក្នុងខែតុលា ឆ្នាំ២០១៧នេះ៖ តួលេខមានដូចក្នុងតារាងខាងក្រោម៖

***តារាងតាមដានបច្ចុប្បន្នភាពទិន្នន័យពលករខ្មែរចំណាកស្រុក ប្រចាំខែតុលា ២០១៧***

| ប្រចាំខែ | សរុបរួម | | | | ស្របច្បាប់ | | | | មិនស្របច្បាប់ | | | | សម្គាល់ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | សរុប | ស្រី | អនីតិជន | | សរុប | ស្រី | អនីតិជន | | សរុប | ស្រី | អនីតិជន | | |
| | | | សរុប | ស្រី | | | សរុប | ស្រី | | | សរុប | ស្រី | |
| តុលា | ៣១៥.៥៦១ | ១៤១.៣១៨ | ៩.០៧១ | ៣.៤២៨ | ១៧៤.៧៦៨ | ៨៤.៨៤២ | ១.១៩១ | ៥៥៩ | ១៤០.៧៩៣ | ៥៦៤៧៦ | ៧.៨៨០ | ២.៨៦៩ | ចំយុះ ១.៦២១ |

**ខ.៥.២ __ការតាមដានស្ថិតិពលករ ដែលត្រូវបានចាប់បញ្ជូនដោយអាជ្ញាធរបរទេសតាមច្រកព្រំដែន__**

- **អគ្គនាយកដ្ឋានអន្តោប្រវេសន៍** បានទទួលពលរដ្ឋខ្មែរដែលអាជ្ញាធរបរទេសបញ្ជូនត្រឡប់មកវិញ ចំនួន**១៧៤**លើក មនុស្សចំនួន៤.០៩៨នាក់ (ស្រី**១.២៨៨**នាក់ និងកុមារ**៤០២**នាក់) ក្នុងនោះតាមច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិចំនួន**១៩**លើក មនុស្សចំនួន**៥៤**នាក់ ស្រី**២២**នាក់ តាមច្រកទ្វារព្រំដែនកម្ពុជា-ថៃចំនួន**១៥២**លើក មនុស្សចំនួន៤.០២២នាក់ (ស្រី**១.២៥០**នាក់ កុមារ៤០២នាក់) ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិបាវិតចំនួន០១លើក មនុស្សចំនួន ០២នាក់(ស្រី) និងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិព្រៃវ័ល្លិ៍ចំនួន០២លើក មនុស្សចំនួន២០នាក់ ស្រី១៤នាក់។

***__ស្ថានភាព៖__***

- ❖ **អគ្គបញ្ជាការដ្ឋាន ទីចាត់ការព្រំដែន** បានទទួល និងសម្ភាសន៍ពលករខ្មែរដែលអាជ្ញាធរថៃ បញ្ជូនមកវិញតាមបណ្ដាខេត្តជាប់ព្រំដែនកម្ពុជា-ថៃ ចំនួន**៣.០២៨**នាក់ ស្រី**១.០៣៣**នាក់ អនីតិជន**៣៦៧**នាក់។
- ❖ **ក្រុមអនុវត្តន៍ច្បាប់**រាយការណ៍ថា មានពលរដ្ឋខ្មែរចំនួន**១៩៨**នាក់ ត្រូវអាជ្ញាធរថៃឃាត់ខ្លួនពីបទឆ្លងដែនខុសច្បាប់ ហើយថៃឃាត់ខ្លួនលើសពីរយៈពេល១ខែមុននឹងបញ្ជូនមកកម្ពុជាវិញ។
- ❖ **ខេត្តបន្ទាយមានជ័យ** អាជ្ញាធរថៃបានបញ្ជូនពលករខ្មែរត្រឡប់មកប្រទេសកម្ពុជាវិញ ក្រោមរូបភាព «**និរទេស**» តាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត សរុបមានចំនួន**៧៥**ជើង/រថយន្ត មនុស្សចំនួន**៣.០៩៧**នាក់ (ស្រី**១.០៨៩**នាក់) ក្នុងនោះកុមារ**៣៦៣**នាក់ (កុមារី**១៤៤**នាក់)

បើប្រៀបធៀបនឹងខែមុនមានការថយចុះ**២៦៣**នាក់) ស្មើនឹង**៧.៨២%**។ ក្រោយពីធ្វើការសម្ភាសរួច បានឲ្យយើងដឹងថា៖

- ចេញតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែតចំនួន**៩៥៦**នាក់ តាមច្រករបៀងមាន**២.១៤១៤**នាក់ ក្នុងនោះចេញដោយខ្លួនឯងមាន**១.២២៧៩០**នាក់ និងតាមគេនាំមាន**១.៩៧០**នាក់។

❖ **ខេត្តបាត់ដំបង** ទទួលពលករខ្មែរ ដែលអាជ្ញាធរថៃចាប់បញ្ជូនមកវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិដូង ចំនួន០៦លើក មនុស្សចំនួន**២៦**នាក់ ស្រី០៩នាក់ កុមារ**១៨នាក់**។

❖ **ខេត្តប៉ៃលិន** ទទួលពលករខ្មែរ ដែលវិលត្រឡប់ពីប្រទេសថៃដោយខ្លួនឯងចំនួន**៣០**លើក មនុស្សចំនួន**៣៤២**នាក់ ស្រី**១៤០**នាក់។

- **ដោយឡែក យោងតាមរបាយការណ៍អគ្គនាយកដ្ឋានអន្តោប្រវេសន៍** បានរកឃើញជនបរទេសដែលមកធ្វើការនៅក្នុងប្រទេសកម្ពុជាដោយខុសច្បាប់ និងត្រូវបណ្តេញចេញ:

- **ឆ្លងដែន និងស្នាក់នៅខុសច្បាប់** ចំនួន២៣លើក មនុស្សចំនួន៤៤នាក់ (ស្រី០៨នាក់) មាន១១សញ្ជាតិ ក្នុងនោះ៖(វៀតណាម១៧នាក់ ស្រី០៨នាក់, ចិន០៨នាក់, ម៉ុងតាញ៉ា០៧នាក់, នីហ្សេរីយ៉ា០៤នាក់, បេឡារ៉ូស០២នាក់, កាណាដា០១នាក់, កូឌីវ័រ០១នាក់, អង់គ្លេស០១នាក់, អ៊ុយក្រែន០១នាក់, អាមេរិក០១នាក់ និងហ្វីលីពីន០១នាក់) ក្នុងករណីខាងលើ មុននឹងបញ្ជូនចេញទៅប្រទេសដើមវិញ ត្រូវបានបោះត្រាហាមចូលប្រទេសកម្ពុជាលើលិខិតឆ្លងដែន។

- **ការត្រួតពិនិត្យតាមសហគ្រាស និងគ្រឹះស្ថាននានា តាមបណ្តារាជធានី/ខេត្ត** បានចំនួន**៣៣២**គោលដៅ ពលករបរទេសចំនួន**១.៨៥៨**នាក់ ស្រី**៦៤៩**នាក់ មាន**២៣**សញ្ជាតិ៖ **មានប័ណ្ណការងារ**: ចំនួន ១.៨០៨នាក់ ផាកពិន័យចំនួន**៣០**ក្រុមហ៊ុន និង**គ្មានប័ណ្ណការងារ**: ចំនួន៥០នាក់ ពិន័យជាប្រាក់ចំនួន២៥.០០០.០០០រៀល (ម្ភៃប្រាំលានរៀលគត់)។

**ខ.៦-ការបង្ការ ទប់ស្កាត់ការជួញដូរមនុស្សតាមរយៈការរៀបអាពាហ៍ពិពាហ៍ខ្មែរនិងជនបរទេស**

អគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រុមការងារអនុវត្តន៍ច្បាប់) បានធ្វើការសម្ភាសពលរដ្ឋខ្មែរ និងជនបរទេសចំនួន៨៦គូ ដែលបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់។ បានទំនាក់ទំនងនារីខ្មែរដែលទៅរស់នៅជាមួយស្វាមីឯក្រៅប្រទេសតាមរយៈទូរស័ព្ទផ្ទាល់ ដើម្បីតាមដានស្ថានភាពដែលសង្ស័យថាអាចកើតមានការជួញដូរមនុស្សតាមរយៈការរៀបអាពាហ៍ពិពាហ៍ (រស់នៅជាមួយគ្រួសារសុខសប្បាយជាធម្មតា)។

## គ. ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស

### គ.១ ការងារអនុវត្តច្បាប់

គ.១.១-<u>ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ</u>

អគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រុមការងារអនុវត្តន៍ច្បាប់) និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត និងកងរាជអាវុធហត្ថលើផ្ទៃប្រទេស បានខិតខំតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទបានចំនួន១៨/១៦ករណី (ប្រៀបធៀបនឹងខែមុនកើនឡើង០២ករណី) ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងចំនួន**២២**នាក់ (ស្រី**០៧**នាក់) យើងបានសង្គ្រោះជនរងគ្រោះចំនួន**២៤**នាក់ ក្នុងនោះអាយុក្រោម១៥ឆ្នាំ**០៧**នាក់ អាយុពី១៥-១៧ឆ្នាំ០៨នាក់ និងអាយុ១៨ឆ្នាំឡើង០៩នាក់ (ប្រគល់ឲ្យមន្ទីរសង្គមកិច្ចចំនួន០៦នាក់ អង្គការ០១នាក់ និងគ្រួសារចំនួន**១៧**នាក់)។ Ritha

**១. ករណីអំពើជួញដូរមនុស្ស៖**

បង្រ្កាបបាន០៨/០៦ករណី (កើនឡើង០២ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន១០នាក់ (ជនបរទេសសញ្ជាតិរុស្ស៊ី០១នាក់)ស្រី០៤នាក់ ជនរងគ្រោះចំនួន១១នាក់ អាយុក្រោម១៥ឆ្នាំ០២នាក់ អាយុ១៥-១៧ឆ្នាំ០៤នាក់ និងអាយុ១៨ឆ្នាំឡើង០៥នាក់ (ប្រគល់ឲ្យអង្គការ០១នាក់ និងគ្រួសារ១០នាក់) ដូចមានរាយលម្អិតក្នុងតារាងខាងក្រោម៖

*តារាងស្ថិតិបទល្មើសជួញដូរមនុស្ស*

| បទល្មើស | ករណី | ជនសង្ស័យ | ជនបរទេស |
|---|---|---|---|
| -ការនាំយកអនីតិជនជាអាទិ៍ចេញដោយមិនស្របច្បាប់ | ៣ | ៣ | |
| -ការនាំយកចេញដោយមិនស្របច្បាប់ដោយមានគោលដៅ | ២ | ២ | |
| -ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់កេងប្រវ័ញ្ចន៍ | ១ | ១ | រុស្ស៊ី១ |
| -អំពើលក់ដូរមនុស្សដោយមានគោលដៅ | ១ | ៣ | |
| -ការទិញពេស្យាចារកុមារ | ១ | ១ | |
| *សរុប* | *០៨ ករណី* | *១០ នាក់* | *០១ នាក់* |

**២.អំពើធ្វើអាជីវកម្មផ្លូវភេទ៖**

បង្រ្កាបបាន១០/១០ករណី ឃាត់ខ្លួនជនសង្ស័យចំនួន១២នាក់ (សញ្ជាតិវៀតណាម០១នាក់) ស្រី០៣នាក់ ជនរងគ្រោះចំនួន១៣នាក់ អាយុក្រោម១៥ឆ្នាំ០៥នាក់ អាយុ១៥-១៧ឆ្នាំ០៤នាក់ និងអាយុ១៨ឆ្នាំឡើង០៤នាក់ (ប្រគល់ឲ្យមន្ទីរសង្គមកិច្ច០៦នាក់ និងគ្រួសារ០៧នាក់) ដូចមានរាយលម្អិតក្នុងតារាងខាងក្រោម៖

*តារាងស្ថិតិបទល្មើសអាជីវកម្មផ្លូវភេទ*

| បទល្មើស | ករណី | ជនសង្ស័យ | ជនបរទេស |
|---|---|---|---|
| -សញ្ចារកម្ម (មានអនីតិជន) | ១ | ១ | |
| -សញ្ចារកម្ម (ទាក់ទងនឹងពេស្យាចារកុមារ) | ១ | ៣ | វៀតណាម១ |
| -រូបភាព និងសម្ភារៈអាសអាភាស | ១ | ១ | |
| -អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | ៦ | ៦ | |
| -អំពើអាសប្រឆាំងនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ | ១ | ១ | |
| *សរុប* | *១០ ករណី* | *១២ នាក់* | *០១ នាក់* |

## ឃ.កិច្ចការពារជនរងគ្រោះ និងការផ្តល់សេវាគាំទ្រ

**ឃ.១-ការសម្ភាសន៍ពលករបញ្ជូនត្រឡប់តាមច្រកព្រំដែន (ផ្លូវគោក និងផ្លូវអាកាស) ដើម្បីកំណត់មុខសញ្ញារងគ្រោះ និងជនសង្ស័យ**

យោងស្ថិតិ **អគ្គស្នងការដ្ឋាននគរបាលជាតិ** (របាយការណ៍ក្រុមការងារអនុវត្តន៍ច្បាប់) បានធ្វើសម្ភាសន៍ពលកររងគ្រោះចំនួន០៧នាក់(ស្រី) ក្នុងនោះមកពីប្រទេសចិន០៥នាក់(ស្រីនាក់) និងប្រទេសវៀតណាម០២នាក់ (ស្រី)តាមការសម្ភាសជនរងគ្រោះទៅតាមរយៈមេខ្យល់ទាំងអស់។

**ឃ.២-ការទទួលជនសង្ស័យរងគ្រោះ**

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនិតិសម្បទា **(ក្រុមការងារការពារជនរងគ្រោះ)** ដោយមានកិច្ចសហការជាមួយអង្គការ IOM អង្គការចាប់ដៃ អង្គការរតនៈអ៊ិនធើនេសិនណល និងអង្គការADHOC បានទទួលជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស មាតុភូមិនិវត្តន៍ និងនីរទេសពីប្រទេសនានា សរុបចំនួន ២២នាក់ (ស្រី០៩នាក់) កុមារ១២នាក់(កុមារី០៦នាក់) មានដូចជាៈ ប្រទេសថៃ១០នាក់ ចិន០៤នាក់ វៀតណាម០៤នាក់ និងប្រទេសម៉ាឡេស៊ី០៤នាក់។

**ឃ.៣-ការជួយជនរងគ្រោះ និងជនងាយរងគ្រោះ និងសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស**

- **សមាហរណកម្មជនរងគ្រោះ**

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (**ក្រុមការងារការពារជនរងគ្រោះ**) និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត បានសហការជាមួយអាជ្ញាធរមូលដ្ឋាន អង្គការចាប់ដៃ និងអង្គការរតនៈអ៊ិនជើនេសិនណល បានសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស ទៅតាមសហគមន៍វិញចំនួន០៤នាក់(ស្រី)។

## III. ការលើកកម្ពស់សមត្ថភាព

### ១. ក្នុងប្រទេស

**១.១-ការបណ្តុះបណ្តាល**

អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានសហការជាមួយជំនាញតាមក្រសួង មន្ទីរ អង្គភាព និងអង្គការដៃគូ បើកវគ្គបណ្តុះបណ្តាល បានចំនួន០៤វគ្គ មានសិក្ខាកាមចូលរួមចំនួន**២៨៩**នាក់ ក្នុងនោះមានស្ត្រី**១៣៧**នាក់ ដើម្បីពង្រឹងសមត្ថភាពគ្រូបង្គោល មន្ត្រីអនុវត្តន៍ច្បាប់ សមាជិកគ.ខ.ប.ជ លោកគ្រូ អ្នកគ្រូ និងប្រជាពលរដ្ឋ មានតារាងលម្អិតខាងក្រោម៖

*តារាងវគ្គបណ្តុះបណ្តាល*

| ល.រ | ស្ថាប័នអនុវត្ត និងវគ្គបណ្តុះបណ្តាល | ចំនួនវគ្គ | សិក្ខាកាមសរុប | សិក្ខាកាមនារី |
|---|---|---|---|---|
| ១ | **អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ** សហការជាមួយក្រសួងសង្គមកិច្ច និងនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរ បាលជាតិ និងអង្គការ Child Fund, IOM បានចុះបណ្តុះបណ្តាល ស្តីពីការកំណត់អត្តសញ្ញាណ ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវា សមស្រប (ខេត្តតាកែវ និងខេត្តកំពង់ឆ្នាំង)។ | ២ | ១៤០ | ៥១ |
| ២ | **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** បើកវគ្គបណ្តុះបណ្តាល ស្តីពីបទដ្ឋានអប្បបរមា សម្រាប់ថែទាំជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទដែលស្នាក់នៅក្នុងមណ្ឌល និងបទដ្ឋានអប្បបរមាស្តីពី កិច្ចការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅខេត្តព្រះសីហនុ ដល់មន្ទីរ ស.អ.យ ២៥រាជធានី-ខេត្ត និងអង្គការដៃគូពាក់ព័ន្ធ១៣។ | ០១ | ៦៧ | ២៩ |
| ៣ | **មន្ទីរសង្គមកិច្ចខេត្តព្រះសហនុ** បើកវគ្គបណ្តុះបណ្តាលបទដ្ឋានអប្បបរមា សម្រាប់ការថែទាំជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងគោលការណ៍ណែនាំ ស្តីពីបែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប។ | ០១ | ៨២ | ៥៧ |
| | *សរុប* | *០៤វគ្គ* | *២៨៩ នាក់* | *១៣៧ នាក់* |

**១.២-សិក្ខាសាលា៖**

លេខាធិការដ្ឋាន គ.ខ.ប.ជ បានសហការជាមួយអង្គការដៃគូ ដោយមានការសម្របសម្រួល ពីអគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានរៀបចំសិក្ខាសាលា ប្រធានបទសំខាន់ផ្តោតទៅលើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស សរុបចំនួន**០៥វគ្គ** អ្នកចូលរួមចំនួន**២៨១**នាក់ ស្រី**៨៣**នាក់ ក្នុងនោះមាន៖

- **ខេត្តបន្ទាយមានជ័យ** បានរៀបចំសិក្ខាសាលា ស្តីពីកិច្ចសហការដើម្បីប្រយុទ្ធប្រឆាំងជួញដូរមនុស្ស នៅសាលប្រជុំ (ក) ខេត្តបន្ទាយមានជ័យ ក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ អ្នកចូលរួមចំនួន**១១៥**នាក់ ស្រី**៤១**នាក់។

- **លេខាធិការដ្ឋានខេត្តកោះកុង** សហការជាមួយអង្គការវីកអន្តរជាតិ បានបើកវគ្គសិក្ខាសាលា ស្តីពីការបណ្តុះបណ្តាល ដល់មន្ត្រីជួរមុខនៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្ត ក្រោមអធិបតីភាពលោកស្រី **ឈុន វ៉ាវុធ** អភិបាលរងខេត្ត អ្នកចូលរួមសរុប៤៥នាក់ ស្រី១៦នាក់។
- **មជ្ឈមណ្ឌលការងារខេត្តបាត់ដំបង** រៀបចំសិក្ខាសាលា០៣វគ្គ អ្នកចូលរួមសរុប១២១នាក់ ស្រី២៦នាក់៖
  - ស្តីអំពីការផ្សព្វផ្សាយសេវាការងារ និងប្រមូលអ្នកស្វែងរកការងារ ធ្វើតាមមូលដ្ឋាន នៅសាលាស្រុកមោងឫស្សី ខេត្តបាត់ដំបង អ្នកចូលរួមសរុប៥០នាក់ ស្រី០៥នាក់។
  - ស្តីពីការរៀបចំផែនការអាជីពការងារ និងវិជ្ជាជីវៈ នៅសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា ខេត្តបាត់ដំបង អ្នកចូលរួមសរុប២៨នាក់ ស្រី១២នាក់។
  - ស្តីអំពីការផ្សព្វផ្សាយសេវាការងារ និងប្រមូលអ្នកស្វែងរកការងារ ធ្វើតាមមូលដ្ឋាន នៅសាលាស្រុកថ្មគោល ខេត្តបាត់ដំបង អ្នកចូលរួមសរុប៤៣នាក់ ស្រី០៩នាក់។

**១.៣-សន្និសីទ**

- **អគ្គនាយកដ្ឋានអន្តោប្រវេសន៍** បានរៀបចំសន្និសីទអាស៊ី-អឺរ៉ុបលើកទី១៤ ស្តីពីការគ្រប់គ្រងលំហូរទេសន្តរប្រវេសន៍ ក្រោមអធិបតីភាព សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅខេត្តសៀមរាប មានសមាជិកចូលរួមចំនួន៦៤នាក់មកពី២៥ប្រទេស ។

**១.៤-កិច្ចប្រជុំការងារដឹកនាំសម្របសម្រួល៖**

ដោយគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ ចំនួន២០លើក ក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទាចំនួន០១លើក និងលេខាធិការដ្ឋាន រាជធានី-ខេត្តចំនួន២០លើក សរុបកិច្ចប្រជុំ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សទូទាំងប្រទេសសរុប៤១លើក មានអ្នកចូលរួមសរុប៤៧២នាក់ស្រី២០២នាក់។ (**ឧបសម្ព័ន្ធទី២**)

## ២. ក្រៅប្រទេស

**២.១.ការចូលរួមកិច្ចប្រជុំ**

- **អគ្គនាយកដ្ឋានអន្តោប្រវេសន៍** ចាត់បញ្ជូននាយនគរបាលជាន់ខ្ពស់០១រូប ចូលរួមជាអ្នកធ្វើបាយការណ៍លើវិស័យទី៣ កិច្ចសហប្រតិបត្តិការអន្តរជាតិ និងអភិបាលកិច្ចនៃទេសន្តរប្រវេសន៍ ក្នុងគ្រប់ទិដ្ឋភាពរួមមាន ច្រកព្រំដែនការឆ្លងកាត់ ការចូលការវិលត្រឡប់ ការទទួលឲ្យធ្វើការវិញ សមាហរណកម្មឡើងវិញ (ប្រទេសថៃ)។

# IV. ការសន្និដ្ឋានវាយតម្លៃ

## ក.ចំណុចខ្លាំង

តាមរយៈការខិតខំប្រឹងប្រែង អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ សម្រេចការងារជាលទ្ធផលជោគជ័យគួរកត់សម្គាល់៖

- ការគាំទ្ររបស់រាជរដ្ឋាភិបាល បានកំណត់យកបញ្ហាជួញដូរមនុស្សជាការងារសំខាន់ដែលត្រូវយកចិត្តទុកដាក់ និងផ្តល់អាទិភាពរកដំណោះស្រាយ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងថ្នាក់អន្តរជាតិផងដែរ។
- ការយកចិត្តទុកដាក់របស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** **នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានផ្តល់អនុសាសន៍ **០៤ចំណុច** និងវិធានការ **០៦ចំណុច** របស់សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាប្រធាន គ.ជ.ប.ជ គឺជាប្រទីបដ៏ល្អដល់គ.ជ.ប.ជ និងគ្រប់សមាសភាពដែលជាយន្តការក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

- យើងមានច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ និងបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមូលដ្ឋានបង្អែក សម្រាប់ការអនុវត្តទប់ទល់ទៅនឹងបទល្មើសទាំងឡាយដែលកើតឡើង។
- យើងបានចុះសន្ធិសញ្ញា បត្យាប័ន អនុសញ្ញា អនុស្សរណៈនៃការយោគយល់គ្នា កិច្ចព្រមព្រៀង និងលិខិតបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមួយប្រទេសជិតខាងក្នុងតំបន់ និងសកលលោក លើវិស័យប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អំពើពេស្យាចារ រំលោភផ្លូវភេទ ជួញដូរស្ត្រី និងកុមារ...។ល។
- យើងមានយន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលជាកម្លាំងស្នូលក្នុងការអនុវត្តការងារនេះ។ ហើយតាមក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជន សុទ្ធតែបានចូលរួមយ៉ាងសកម្មក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើអសកម្មទាំងឡាយក្នុងសង្គមកម្ពុជា។
- ការកៀងគរកម្លាំង និងការជួយឧបត្ថមពីអង្គការជាតិ អន្តរជាតិ វិស័យឯកជន និងថវិកាតាមក្រសួង ស្ថាប័ន អង្គភាពរៀបចំសម្រាប់ការអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

**ខ. ចំណុចខ្វះខាត ឬគោលប្រឈម**

ទន្ទឹមនឹងការខិតខំប្រឹងប្រែង និងចំណុចខ្លាំងខាងលើ យើងពិនិត្យឃើញនៅមានចំណុចប្រឈម នឹងសេសសល់មួយចំនួនដូចជា ៖

- ថ្វីត្បិតតែយើងបានបង្កើតក្រសួង ស្ថាប័ន អង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សម្រាប់ជាយន្តការក្នុងការសហការ និងសហប្រតិបត្តិការគ្នា តែអង្គភាពមួយចំនួននៅមិនទាន់ចេះសហការគ្នា ជាប្រព័ន្ធ និងបែងចែកការទទួលខុសត្រូវបន្តហូតចប់ការងារ។
- ការធ្វើរបាយការណ៍នៅយឺតយ៉ាវ របាយការណ៍ភាគច្រើនមិនបានសម្រិតសម្រាំងឲ្យចេញពីសកម្មភាពអំពើជួញដូរមនុស្ស។
- មន្ត្រីយើងនៅមិនទាន់យល់ច្បាស់ពីប្រភេទការងារណា ដែលទាក់ទងនឹងអំពើជួញដូរមនុស្ស ដូចនេះពេលខ្លះយើងខ្វះអ្នកសហការ។
- របាយការណ៍សំខាន់ណាស់សម្រាប់ក្រសួង ស្ថាប័ន អង្គភាពបើរបាយការណ៍ល្អ នោះបញ្ជាក់ថាក្រសួង ស្ថាប័ន ឬអង្គភាពនោះមានស្នាដៃ សកម្ម ហើយកិត្តិយសក្រសួង ស្ថាប័ន អង្គភាពក៏បានល្អដែរ។ ឧទាហរណ៍ ក្រសួង ស្ថាប័ន ឬអង្គភាព បានធ្វើការងារច្រើនទាក់ទងនឹងការងារអំពើជួញដូរមនុស្ស តែមន្ត្រីធ្វើរបាយការណ៍មិនយល់ ឬមិនបានសរសេរអស់នូវសកម្មភាព និងទិន្នន័យដែល ក្រសួង ស្ថាប័ន ឬអង្គភាពខ្លួនបានធ្វើ ដូច្នេះកិត្តិយស ក្រសួង ស្ថាប័ន អង្គភាពនោះក៏មិនអស់តាមរបាយការណ៍នោះដែរ។

**គ.សំណូមពរ**

- គ្រប់ក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជនត្រូវយកចិត្តទុកដាក់ទំនាក់ទំនង សហប្រតិបត្តិការ និងសាមគ្គីធ្វើការងារជាប្រព័ន្ធតាមជំនាញរៀងៗខ្លួន។
- បើកវគ្គបណ្តុះបណ្តាលដល់មន្ត្រីទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ឲ្យយល់ពីការងារដែលទាក់ទងនឹងអំពើជួញដូរមនុស្ស តាមវិស័យនីមួយៗរបស់ខ្លួន។
- ក្រសួង ស្ថាប័ន អង្គភាពទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ យកចិត្តទុកដាក់អនុវត្តតាមសេចក្តីសម្រេចស្តីពីការតែងតាំងសមាសភាពក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលប្រធាន គ.ជ.ប.ជ បានសម្រេច។

**ឃ. សន្និដ្ឋាន**

ការតាមដានត្រួតពិនិត្យ ត្រូវបានធ្វើឡើង ៖ Putha

- យើងមានការគាំទ្រ និងការយកចិត្តទុកដាក់ពីថ្នាក់ដឹកនាំ គ.ជ.ប.ជ និងរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា។ គោលនយោបាយល្អ និងការប្តេជ្ញាចិត្តខ្ពស់ មានឆន្ទៈមោះមុត មានសាមគ្គីភាព កិច្ចសហការប្រតិបត្តិការល្អ នោះយើងនឹងសម្រេចបាននូវលទ្ធផលជាទីគាប់ចិត្ត រួមកាត់បន្ថយបាននូវអំពើអសកម្មក្នុងសង្គម។
- ពីមួយថ្ងៃទៅមួយថ្ងៃមន្ត្រីយើងកាន់តែយល់ដឹង កាន់តែមានជំនាញ មានបទពិសោធន៍ ការងារកាន់តែស៊ីជម្រៅការទំនាក់ទំនងថ្នាក់ជាតិ និងអន្តរជាតិ កាន់តែច្រើន ធ្វើឲ្យយើងកាន់តែមើលឃើញនូវភាពខ្វះចន្លោះក្នុងកិច្ចការ និងមើលឃើញនូវតម្រូវការ ទាំងធនធានមនុស្ស សម្ភារៈ និងការចងក្រងលិខិតបទដ្ឋានគតិយុត្តិនានា ដើម្បីសម្របសម្រួលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែមានប្រសិទ្ធភាព និងភាពរីកចម្រើន។
- បើយើងរៀបចំសកម្មភាព ផែនការអនុវត្ត និងផែនការយុទ្ធសាស្ត្របានល្អ យើងនឹងរៀបចំផែនការថវិកាកាន់តែប្រសើរសម្រាប់ការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- ប្រសិនបើប្រជាពលរដ្ឋដែលជាអ្នកទទួលសេវាមានការយល់ដឹងច្រើន ពីអំពើជួញដូរមនុស្ស មានការប្រុងប្រយ័ត្ន មិនលង់តាមការណែនាំ បោកបញ្ឆោតពីពួកឱកាសនិយម និងបានចូលរួមសហការជាមួយអ្នកបម្រើសេវា នៃក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជន នោះការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែទទួលបានជោគជ័យក្នុងសង្គមកម្ពុជាមិនខាន។

## V. ទិសដៅខែវិច្ឆិកា ឆ្នាំ២០១៧

ដើម្បីកែលម្អចំណុចខ្វះខាត និងពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រទាំងបួន ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរបៀបរបបការងារឲ្យកាន់តែល្អប្រសើរ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដាក់ចេញនូវទិសដៅដូចខាងក្រោម ៖

១. បន្តពង្រឹងកិច្ចសហការទូលំទូលាយតាមរយៈ ការជួបប្រជុំពិភាក្សា បង្កើតសកម្មភាពផ្អែកលើយុទ្ធសាស្ត្ររួមដែលបានកំណត់ និងចូលរួមបែងចែកភារកិច្ច ពង្រាយកម្លាំង និងការទទួលខុសត្រូវ ឆ្ពោះទៅកាន់គោលដៅរួម គឺការបង្ការ ទប់ស្កាត់ ឈានទៅលុបបំបាត់អំពើជួញដូរមនុស្សគ្រប់រូបភាព។

២. ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តវិធានការជាអាទិភាព ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ្រប់រូបភាព ជាអាទិ៍៖ អំពើជួញដូរ និងកេងប្រវ័ញ្ចកម្លាំងពលកម្ម ជួញដូរផ្លូវភេទ ការដកហូតសរីរាង្គ ការរត់ពន្ធទារក និងកុមារឆ្លងដែន ការពពោះជំនួស និងការជួញដូរពលកម្ម ក្នុងឧស្សាហកម្មនេសាទសមុទ្រ...។ល។

៣. រៀបចំផែនការសកម្មភាពជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(ពាក់កណ្ដាលអាណត្តិទី២៖២០១៧-២០១៨)។

៤. ត្រៀមចុះហត្ថលេខាលើកិច្ចព្រមព្រៀងទ្វេភាគីកម្ពុជា-ឥណ្ឌា និងជាមួយប្រទេសពាក់ព័ន្ធដទៃទៀត។

៥. ត្រៀមកិច្ចប្រជុំពិគ្រោះយោបល់រវាងក្រុមប្រទេសបញ្ជូន និងប្រទេសទទួល (ថៃ ម៉ាឡេស៊ី..) ដើម្បីពង្រឹងកិច្ចសហការ ចែករំលែកការទទួលខុសត្រូវ និងការពារផលប្រយោជន៍ពលករ ជាពិសេសពលករក្នុងឧស្សាហកម្មនេសាទ ព្រមទាំងនិយោជក រវាងប្រទេសបញ្ជូន និងប្រទេសទទួលប្រកបដោយសមធម៌។

៦. គាំទ្រ និងពង្រឹងសមត្ថភាពជំនាញពាក់ព័ន្ធគ្រប់ផ្នែក ដល់មន្ត្រីជំនាញ ពង្រឹងការគ្រប់គ្រង របៀបរបបការងាររបស់ក្រុមការងារ និងលេខាធិការដ្ឋានរាជធានី-ខេត្ត។

៧. បន្តការងារផ្សព្វផ្សាយអប់រំតាមគ្រប់រូបភាព និងប្រើគ្រប់លទ្ធភាព និងធនធាន ដើម្បីលើកកម្ពស់ការយល់ដឹងជាសកល អំពីការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ទំនាក់ទំនងរវាងទេសន្តរប្រវេសន៍ និងអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀត ឲ្យបានដល់ប្រជាពលរដ្ឋ ជាពិសេសស្រទាប់យុវវ័យ ក្នុងសាលារៀន និងក្រៅសាលារៀន និងជនដែលងាយរងគ្រោះ។

៨. បន្តរៀបចំសកម្មភាពបណ្តុះបណ្តាល មន្ត្រីពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះនៅតាមបណ្តាក្រសួង ស្ថាប័នអង្គការដៃគូក្នុងស្រុកនិងមន្ត្រីប្រចាំស្ថានទូតកម្ពុជា ក្នុងប្រទេសគោលដៅ ព្រមទាំងចុះតាមដានការអនុវត្ត។

៩. បន្តតាមដានលទ្ធផល និងប្រសិទ្ធភាពនៃការអនុវត្តកិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី និងគាំទ្រដល់ការអនុវត្តអនុសញ្ញាអាស៊ានប្រឆាំងការជួញដូរមនុស្សដែល សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានចុះហត្ថលេខារួមគ្នា កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៥។

១០. ជំរុញតាមដានត្រួតពិនិត្យក្រុមហ៊ុនបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេស ឲ្យអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលឲ្យបានត្រឹមត្រូវ។

១១. បន្តរៀបចំវិធានការ *"គ្រប់គ្រងលំហូរ ពលករទេសន្តរប្រវេសន៍ការឆ្លងដែនមិនប្រក្រតី"* (គោរពតាមអនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ ) ។

១២. ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេសការពង្រឹងកិច្ចសហការក្នុងការជួយគ្នាទៅវិញទៅមក ក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ ជាមួយប្រទេសពាក់ព័ន្ធ។

១៣. បន្តអនុវត្ត និងចូលរួមយ៉ាងសកម្ម ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព របស់រាជរដ្ឋាភិបាល ។

**ទិសដៅបន្ថែម ដែលជាអនុសាសន៍សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្នុងកិច្ចប្រជុំឆមាសទី១ នេះ ដែលគប្បីជំរុញអនុវត្ត ឲ្យមានប្រសិទ្ធភាព សម្រាប់ដំណាក់កាលដ៏ចាំបាច់៖**

១៤. ជំរុញអនុវត្តវិធានការ ដែលដាក់ចុះដោយក្រសួងមហាផ្ទៃ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងការបរទេស ក្នុងដំណាក់កាលនៃការជំរុញដំណោះស្រាយភាពស្របច្បាប់ដល់ពលករ ដែលនៅក្នុងប្រទេសថៃ និងការទទួលខុសត្រូវរបស់អាជ្ញាធរ សមត្ថកិច្ចពាក់ព័ន្ធ ក្នុងការជួយដល់ពលករដែលត្រូវបានបញ្ជូនត្រឡប់។

១៥. បង្កើតក្រុមការងារ ពិសេសមួយក្រោមគណៈកម្មការផ្តល់ភាពស្របច្បាប់ ដឹកនាំដោយរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីស្រាវជ្រាវ អំពីពលករខ្មែរ ដែលមានវត្តមានក្នុងប្រទេសថៃ ស្ថានភាពស្របច្បាប់ ឬមិនស្របច្បាប់ ទីកន្លែងធ្វើការ អាស័យដ្ឋាននៅកម្ពុជា ដើម្បីងាយស្រួល ក្នុងការដោះស្រាយបញ្ហា និងទំនាក់ទំនងអប់រំ ផ្តល់សេវា និងបង្កើនភាពជឿជាក់ដល់រាជរដ្ឋាភិបាល។

១៦. រៀបចំបែងចែកក្រុមនេះ ដោយស្នើសុំបញ្ចូលជាក្រុមដែលមានបេសកកម្មពិសេស ជា**អនុព័ន្ធការងារ** ក្នុងរយៈពេលខ្លីមួយ ដែលនឹងត្រូវរំសាយវិញ ពេលចប់បេសកកម្ម។

១៧. ជំរុញសាងសង់ជម្រកបណ្តោះអាសន្ន នៅតាមច្រកព្រំដែនសំខាន់ៗ ដែលមានការបញ្ជូនត្រឡប់ពីប្រទេសថៃ នៅតែមានជាប់បន្ត ជារៀងរាល់ថ្ងៃ ដោយមានមន្ត្រីប្រចាំការ សម្រាប់ការផ្តល់សេវាចាំបាច់មួយចំនួន ដូចជាការពិនិត្យ ព្យាបាលសុខភាពបឋម អាហារ សម្រាប់មនុស្សចាស់ កុមារ ទារក ការស្នាក់នៅបណ្តោះអាសន្ន មុនពេលចេញដំណើរ ការសាកសួរសុខទុក្ខ សម្របសម្រួល និងស្តាប់សំណូមពរដើម្បីបន្តដោះស្រាយនៅនឹងកន្លែង ឬ នៅតាមបណ្តាខេត្តប្រភពរបស់ពលករជាដើម។ Ptha

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៧

**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

ជូ_ប៊ុនអេង

**ចម្លងជូន**

- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ

"ដើម្បីគោរពជូនជាសេចក្តីរាយការណ៍"

-ឯកឧត្តម លោកជំទាវ ប្រធានក្រុមការងារជំនាញ អន្តរក្រសួង ស្ថាប័ន

-សមាជិកក្រុមការងារ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

"ដើម្បីជូនជ្រាប"

-ឯកសារ កាលប្បវត្តិ

## ឧបសម្ព័ន្ធទី១

## សកម្មភាពផ្សព្វផ្សាយ និងវេទិកាសាធារណៈក្នុងខែតុលា ឆ្នាំ២០១៧

| ល.រ | របាយការណ៍ពី | ខ្លឹមសារសកម្មភាព | អង្គភាព-ស្ថាប័នអ្នករៀបចំ | ចំនួនលើក | ចំនួនមនុស្ស | ចំនួនស្រី |
|---|---|---|---|---|---|---|
| 1 | ក្រុមការងារអនុវត្តន៍ច្បាប់ | ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងភូមិ-ឃុំមានសុវត្ថិភាព ដល់អាជ្ញាធរមូលដ្ឋាន ប្រជាពលរដ្ឋ លោកគ្រូ-អ្នកគ្រូ និងសិស្សានុសិស្ស។ | ស្នងការដ្ឋាននគរបាលខេត្ត | 776 លើក | 64,362 នាក់ | 36,273 នាក់ |
| 2 | ខេត្តតាកែវ | វេទិកាសាធារណៈ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងអំពើជួញដូរមនុស្ស និងការទប់ស្កាត់ ការជួញដូរកម្លាំងពលកម្មកុមារ ដល់ប្រជាពលរដ្ឋនៅតាមភូមិ/ឃុំ សង្កាត់ ក្រុង/ស្រុក។ | ស្នងការដ្ឋាននគរបាលខេត្ត | 19 លើក | 848 នាក់ | 314 នាក់ |
| | | ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ ស្តីពីការទប់ស្កាត់ការជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព។ | លេខាធិការដ្ឋាន គ.ខ.ប.ជ មន្ទីរកិច្ចការនារីខេត្ត | 31 លើក | 2,786 នាក់ | 1,213 នាក់ |
| 3 | ខេត្តពោធិ៍សាត់ | វេទិកាសាធារណៈ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងអំពើជួញដូរមនុស្ស ដល់ប្រជាពលរដ្ឋ នៅក្រុងពោធិ៍សាត់ ស្រុកក្រគរ ស្រុកភ្នំក្រវាញ និងស្រុកបាកាន។ | លេខាធិការដ្ឋាន គ.ខ.ប.ជ | 70 លើក | 2,471 នាក់ | 1,088 នាក់ |
| | | ផ្សព្វផ្សាយតាមរយៈភូមិ-ឃុំមានសុវត្ថិភាព ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើចំណាកស្រុក ដោយសុវត្ថិភាព ដល់ប្រជាពលរដ្ឋ នៅក្រុងពោធិ៍សាត់ ស្រុកក្រគរ ស្រុកកណ្តៀង ស្រុកភ្នំក្រវាញ និងស្រុកបាកាន។ | ស្នងការដ្ឋាននគរបាលខេត្ត | 277 លើក | 32,111 នាក់ | 10,264 នាក់ |
| 4 | ខេត្តបាត់ដំបង | ផ្សព្វផ្សាយ ស្តីពី ការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់កងកម្លាំងប្រដាប់អាវុធ មន្ត្រីរាជការ និងប្រជាពលរដ្ឋ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត | 1,244 លើក | 66,163 នាក់ | 32,424 នាក់ |
| | | វេទិកាសាធារណៈ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្សលើស្ត្រី និងកុមារ ការធ្វើអាជីវកម្មផ្លូវភេទ និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់កងកម្លាំងប្រដាប់អាវុធ មន្ត្រីរាជការ និងប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត | 621 លើក | 177,769 នាក់ | 9,424 នាក់ |
| 5 | ខេត្តស្វាយរៀង | វេទិកាសាធារណៈ ស្តីពីទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត | 401 លើក | 15,471 នាក់ | 9,592 នាក់ |
| | | ផ្សព្វផ្សាយដល់ពលករ ពលការិនី ស្តីពីការធ្វើចំណាកស្រុកស្វែងរកការងារធ្វើប្រកបដោយសុវត្ថិភាព នៅតាមបណ្តារោងចក្រក្នុងក្រុងបាវិត។ | មន្ទីរការងារ និងបណ្តុះបណ្តាវិជ្ជាជីវៈខេត្ត | 3 លើក | 59 នាក់ | 30 នាក់ |
| 6 | ខេត្តក្រចេះ | ផ្សព្វផ្សាយ ស្តីស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស កិច្ចការពារជនរងគ្រោះ និងការធ្វើចំណាកស្រុក ដោយសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ និងមន្ទីរសង្គមកិច្ចខេត្ត | 9 លើក | 310 នាក់ | 221 នាក់ |

| | | | | | | |
|---|---|---|---|---|---|---|
| 7 | ខេត្តកែប | ផ្សព្វផ្សាយការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តាមរយៈវេទិកាផ្សព្វផ្សាយស្តីពីគោលនយោបាយ ភូម-ឃុំមានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ | 5 លើក | 1,052 នាក់ | 395 នាក់ |
| 8 | ខេត្តកោះកុង | វេទិកាសាធារណៈ ស្តីពីទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត | 38 លើក | 1,451 នាក់ | 639 នាក់ |
| 9 | ខេត្តកណ្តាល | វេទិកាសាធារណៈ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត | 441 លើក | 51,638 នាក់ | 21,155 នាក់ |
| | | ផ្សព្វផ្សាយ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព កិច្ចការពារជនរងគ្រោះ ដល់ប្រជាពលរដ្ឋ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ មន្ទីរអប់រំយុវជន និងកីឡាខេត្ត | 30 លើក | 862 នាក់ | 400 នាក់ |
| 10 | កំពង់ឆ្នាំង | វេទិកាសាធារណៈផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ នូវច្បាប់ស្តីពីអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព។ | ស្នងការដ្ឋាននគរបាលខេត្ត | 482 លើក | 15,443 នាក់ | 10,119 នាក់ |
| | | ផ្សព្វផ្សាយលក្ខណៈសម្បត្តិ៩យ៉ាង អំពីគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ស្តីពីការធ្វើចំណាក ស្រុកដោយសុវត្ថិភាព និងអំពើជួញដូរមនុស្ស ដល់ប្រជាពលរដ្ឋ ។ | ស្នងការដ្ឋាននគរបាលខេត្ត ក្រុមការងារថ្នាក់ភូមិ ស្រុក | 445 លើក | 14,089 នាក់ | 9,129 នាក់ |
| 11 | ខេត្តឧត្តរមានជ័យ | ផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ដល់លោកគ្រូ អ្នកគ្រូ សិស្សានុសិស្សនិងប្រជាពលរដ្ឋក្នុងមូលដ្ឋាន។ | លេខាធិការដ្ឋាន គ.ខ.ប.ជ | 1 លើក | 35 នាក់ | 20 នាក់ |
| 12 | ខេត្តរតនគិរី | វេទិកាសាធារណៈ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត | 2 លើក | 179 នាក់ | 74 នាក់ |
| 13 | ខេត្តព្រះសីហនុ | ផ្សព្វផ្សាយ ស្តីពីទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ អាជ្ញាធរ ភូមិ ក្រុមប្រឹក្សាឃុំ/សង្កាត់ លោកគ្រូ អ្នកគ្រូ និងប្រជាពលរដ្ឋ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ | 1 លើក | 210 នាក់ | 75 នាក់ |

សកម្មភាពសរុបចំនួន: 4,896 លើក

មនុស្សសរុបចំនួន: 447,309 នាក់

ស្រីសរុបចំនួន : 142,849 នាក់

## ឧបសម្ព័ន្ធទី២

## តារាងការងារដឹកនាំ និងសម្របសម្រួល កិច្ចសហប្រតិបត្តិការ (សរុបចំនួន៤១លើក) មនុស្សចំនួន៤៧២នាក់ (ស្រី២០២នាក់)

| ស្ថាប័នសម្របសម្រួល | សកម្មភាព |
|---|---|
| គណៈកម្មាធិការជាតិ គ.ជ.ប.ជ | សម្របសម្រួលចំនួន២០លើក អ្នកចូលរួមសរុបចំនួន១១៨នាក់ (ស្រី៣៤នាក់)<br>- បានអញ្ជើញជួបពិភាក្សាការងារជាមួយលោក **Jesse Lynch** មន្ត្រីទទួលបន្ទុកកិច្ចការនយោបាយ មកពីស្ថានទូតសហរដ្ឋអាមេរិកប្រចាំកម្ពុជា នៅអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។<br>- បានដឹកនាំកិច្ចប្រជុំអន្តរក្រសួង "**ស្តីពីកតិកាសញ្ញាជាសកល ស្តីពីទេសន្តរប្រវេសន៍ប្រកបដោយសុវត្ថិភាព ភាពស្របច្បាប់ និងប្រក្រតីភាព របស់អង្គការសហប្រជាជាតិ**" នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ សមាសភាពចូលរួមចំនួន៣១នាក់ ស្រី០៨នាក់។ (០២លើក)<br>- បានដឹកនាំកិច្ចប្រជុំផ្ទៃក្នុង ស្តីពីការរៀបចំផែនការសកម្មភាពជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ ឆ្នាំ២០១៧-២០១៨ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។<br>- បានអញ្ជើញជាអធិបតី ក្នុងសិក្ខាសាលា ស្តីពីកិច្ចសហការដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរពលកម្ម នៅសាលាខេត្តបន្ទាយមានជ័យ។<br>- បានដឹកនាំកិច្ចប្រជុំអន្តរក្រសួង "**ពិគ្រោះយោបល់លើគោលការណ៍សំខាន់ៗ ដើម្បីប្រមូលធាតុចូលបន្ថែម សម្រាប់សេចក្តីព្រាងច្បាប់ការពពោះជំនួស**" នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ សមាសភាពចូលរួមចំនួន២៥នាក់ ស្រី០៧នាក់។<br>- បានអញ្ជើញចូលរួមប្រជុំជាមួយប្រតិភូការិយាល័យប្រឆាំងការជួញដូរកុមាររបស់សហរដ្ឋអាមេរិក "**ស្តីពីការសិក្សាអំពីសក្តានុពលរបស់កម្ពុជា ក្នុងការទទួលបានមូល និធិនៃភាពជាដៃគូ សម្រាប់កិច្ចការពារកុមារពីអំពើជួញដូរមនុស្ស**" នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។<br>- បានដឹកនាំកិច្ចប្រជុំពិភាក្សាអន្តរក្រសួង "**ស្តីពីការរៀបចំយន្តការអនុវត្តការងារក្រុមការងារទទួលពលករ-ពលការិនីកម្ពុជាខុសច្បាប់មកពីប្រទេសថៃ**" នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ អ្នកចូលរួមចំនួន៣១នាក់ ស្រី១១នាក់។<br>- បានអញ្ជើញចូលរួមកិច្ចប្រជុំ "**ផ្សព្វផ្សាយស្តីពីវិធានការរក្សាសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ និងសវត្ថិភាពសង្គម ប្រឆាំងចំពោះឧបាយកលផ្តួលរំលំរដ្ឋអំណាចស្របច្បាប់ នៅកម្ពុជា**" នៅទីស្តីការក្រសួងមហាផ្ទៃ។<br>- បានដឹកនាំប្រជុំផ្សព្វផ្សាយគោលការណ៍ណែនាំ ស្តីពីវិធានការរក្សាសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម ប្រឆាំងចំពោះឧបាយកលផ្តួលរំលំរដ្ឋអំណាចស្របច្បាប់នៅកម្ពុជា ដល់មន្ត្រីអគ្គលេខាធិការដ្ឋាន គជ ន.ប.ជ.នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន។<br>- បានអញ្ជើញជាអធិបតី ក្នុងសិក្ខាសាលា ស្តីពីកិច្ចសហការដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរពលកម្ម នៅសណ្ឋាគារសុខាអង្គរ ខេត្តសៀមរាប។<br>- បានដឹកនាំកិច្ចប្រជុំពិភាក្សាផ្ទៃក្នុងរៀបចំរបាយការណ៍០៩ខែ ឆ្នាំ២០១៧ និងផែនការសកម្មភាពសម្រាប់អនុវត្តឆ្នាំ២០១៧២០១៨នៅសាលប្រជុំ-អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។<br>- បានអញ្ជើញជួបប្រជុំពិភាក្សាការងារ ជាមួយតំណាងអង្គការ IOM នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន។<br>- បានដឹកនាំកិច្ចប្រជុំពិភាក្សាអន្តរក្រសួង "**ស្តីពីការត្រៀមរៀបចំទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០១៧**" នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន |

| | |
|---|---|
| | មានសមចូលរួមចំនួន៣១នាក់ ស្រី០៨នាក់។<br>- បានអញ្ជើញចូលរួមកិច្ចប្រជុំ "**ស្តីពីការបង្កើតយន្តការផ្តល់លិខិតធ្វើដំណើរជូនពលករកម្ពុជាមានបំណងរកការងារធ្វើ សម្រាប់ខេត្តបាត់ដំបង និងខេត្តបន្ទាយមានជ័យ**" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅទីស្តីការក្រសួងមហាផ្ទៃ។<br>- ដឹកនាំត្រួតពិនិត្យវត្តមាន វិន័យ និងសណ្តាប់ធ្នាប់របស់មន្ត្រីនគរបាល និងមន្ត្រីស៊ីវិលនៃអគ្គលេខាធិការដ្ឋានគ.ជ.ប.ជ ព្រឹកថ្ងៃច័ន្ទ នៃសប្តាហ៍នីមួយៗ។<br>- បានប្រជុំក្រុមជំនួយកិច្ចការ ពិភាក្សាការរៀបចំកម្រងសំនួរសម្រាប់ដាក់ជូនក្រុមការងារបង្ការ ទប់ស្កាត់ បំពេញនូវរាល់សកម្មភាពពាក់ព័ន្ធការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សកន្លងមក ដើម្បីងាយស្រួលក្នុងការប្រមូលទិន្នន័យមកបូកសរុបរបាយការណ៍។<br>- បានជួបពិភាក្សាការងារជាមួយតំណាងវិទ្យាស្ថាន AII ក្នុងគោលបំណង សិក្សាស្រាវជ្រាវ និងចែករំលែកបទពិសោធន៍ការងារទាក់ទងសកម្មភាពរបស់គ.ជ.ប.ជ ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ការងារទេសន្តរប្រវេសន៍រវាងកម្ពុជា-ថៃ និងការកសាងផែនការសកម្មភាព ដើម្បីចូលរួមជាមួយរាជរដ្ឋាភិបាល ជាពិសេសក្នុងបរិបទពលកម្មទេសន្តរប្រវេសន៍កម្ពុជា-ថៃ។<br>- បានចូលរួមពិភាក្សាលើ "**សេចក្តីព្រាងច្បាប់ ស្តីពីការពពោះជំនួស**" នៅទី ស្តីការក្រសួងកិច្ចការនារី។<br>- បានចូលរួមប្រជុំបូកសរុបលទ្ធផលការងារ ០៩ខែ ឆ្នាំ២០១៧ និងផែនការសកម្មភាពឆ្នាំ២០១៧-២០១៨ របស់ក្រុមការងារការពារជនរងគ្រោះ នៅទីស្តីការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ |
| ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | - បានចូលរួមជាគ្រូឧទ្ទេស ក្នុងវគ្គបណ្តុះបណ្តាលរបស់គ.ជ.ប.ជ ស្តីពីបែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប នៅខេត្តតាកែវ។ |
| **លេខាធិការដ្ឋាន គ.ខ.ប.ជ សម្របសម្រួលចំនួន២០លើក អ្នកចូលរួមសរុបចំនួន៣៥៤នាក់ (ស្រី១៥៩នាក់)** | |
| ខេត្តស្វាយរៀង | - ចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីនីតិវិធីនៃការធ្វើអង្កេតបទល្មើសអំពើជួញដូរមនុស្ស នៅខេត្តកំពង់ចាម។ |
| ខេត្តក្រចេះ | - ប្រជុំជាមួយក្រុមការងារអន្តរមន្ទីរ ស្ថាប័នទាំង៦ ស្តីពីការពង្រឹង តួនាទី ភារកិច្ច និងការរៀបចំធ្វើរបាយការណ៍១០ខែ អ្នកចូមរួមចំនួន៥០នាក់ ស្រី២៧នាក់។ |
| ខេត្តព្រះវិហារ | **សម្របសម្រួលចំនួន០២លើក អ្នកចូលរួមសរុបចំនួន២៦នាក់ (ស្រី០៨នាក់)**<br>- កិច្ចប្រជុំ ស្តីពីការពង្រឹងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស លេខាធិការដ្ឋាន គ.ខ.ប.ជ ក្នុងការអនុវត្តផែនការសកម្មភាពចុះផ្សព្វផ្សាយ ទិវាជាតិ ១២ ធ្នូ ឆ្នាំ២០១៧ អ្នកចូលរួមចំនួន២២នាក់ ស្រី០៧នាក់។<br>- កិច្ចប្រជុំរៀបចំផែនការសកម្មភាពរបស់ក្រុមការងារបង្ការ ទប់ស្កាត់ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៃលេខាធិការដ្ឋាន គ.ខ.ប.ជ សម្រាប់ត្រីមាសទី៤ ឆ្នាំ២០១៧ និងលើកទិសដៅឆ្នាំ២០១៨ អ្នកចូលរួមចំនួន០៤នាក់ ស្រី០១នាក់។ |
| ខេត្តបន្ទាយមានជ័យ | - នាយរងការិយាល័យចូលរួមប្រជុំពិគ្រោះយោបល់ ស្តីពីចំណាកស្រុកដោយសុវត្ថិភាព និងការទប់ស្កាត់ការជួញដូរមនុស្សស្ត្រី និងកុមារ នៅសាលាក្រុងប៉ោយប៉ែត រៀបចំដោយអង្គការជំណក់ទឹក។<br>- លោកស្រីស្នងការរងចូលរួមប្រជុំប្រចាំខែ របស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ នៅខេត្ត បន្ទាយមានជ័យ។<br>- លោកស្រីស្នងការរង និងមន្ត្រីការិយាល័យប្រឆាំងការជួញដូរមនុស្សចំនួន ០៦នាក់ ស្រី០២នាក់ ចូលរួមសិក្ខាសាលាស្តីពីកិច្ចសហការដើម្បីប្រយុទ្ធប្រឆាំងអំពើ |

| | |
|---|---|
| | ជួញដូរមនុស្ស នៅសាលាខេត្តបន្ទាយមានជ័យ។<br>- លោកនាយរងការិយាល័យ០១នាក់ បានចូលរួមប្រជុំជំនួបពិភាក្សាការងារផ្លាស់ប្តូរបទពិសោធន៍ និងកិច្ចសហការគ្នាក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្លងដែន និងជួយសង្គ្រោះជនរងគ្រោះរវាងនគរបាលថៃ និងនគរបាលកម្ពុជានៅនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ។ |
| ខេត្តបាត់ដំបង | **សម្របសម្រួលចំនួន០៤លើក អ្នកចូលរួមសរុបចំនួន១៤២នាក់ (ស្រី៤៣នាក់)**<br>- បានរៀបចំកិច្ចប្រជុំ ប្រចាំត្រីមាសទី៣និងបូកសរុបរយៈពេល១០ខែ និងពិភាក្សាពីបញ្ហាជួយពលករត្រឡប់មកវិញ នៅសាលាខេត្តបាត់ដំបង។<br>- បានរៀបចំវេទិកាផ្សព្វផ្សាយស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព អ្នកចូលរួមសរុបចំនួន៦០នាក់ ស្រី៣៣នាក់។<br>- បានចូលរួមជាវាគ្មិនក្នុងសិក្ខាសាលាផ្សព្វផ្សាយ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព សេវាការងារ ក្នុងស្រុក និងប្រមូលអ្នកស្វែងរកការងារតាមមូលដ្ឋាននៅស្រុកមោងឫស្សី នាថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៧ ដែលមានអ្នកចូលរួមសរុប៤១នាក់ ស្រី០៣នាក់។<br>- បានចូលរួមជាវាគ្មិនក្នុងសិក្ខាសាលាផ្សព្វផ្សាយ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព សេវាការងារក្នុងស្រុក និងប្រមូលអ្នកស្វែងរកការងារធ្វើនៅតាមមូលដ្ឋានស្រុកថ្មគោល នាថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៧ ដែលមានអ្នកចូលរួមសរុបចំនួន៤១នាក់ ស្រី០៧នាក់។ |
| ខេត្តកោះកុង | - ចូលរួមសិក្ខាសាលាស្តីពី ពិគ្រោះយោបល់លើជាតុចូលសម្រាប់ការរៀបចំ«**កតិកាសញ្ញាជាសកលស្តីពី ទេសន្តរប្រវេសន៍ប្រកបដោយសុវត្ថិភាព ភាពស្របច្បាប់ និងប្រក្រតីភាព**»ក្រោមអធិបតីភាព សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ នៅសណ្ឋាគារអាំងទ័រកង់ទីណង់តាល់ រាជធានីភ្នំពេញ។<br>- ចូលរួមប្រជុំស្តីពី ការរៀបចំយន្តការអនុវត្តការងារ ក្រុមការងារទទួលពលករ ពលករិនីកម្ពុជាខុសច្បាប់មកពីប្រទេសថៃ នៅអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។ |
| ខេត្តកណ្តាល | **សម្របសម្រួលចំនួន០៣លើក អ្នកចូលរួមសរុបចំនួន៨៩នាក់ (ស្រី៥៩នាក់)**<br>- ក្រុមការងារថ្នាក់ស្រុក រៀបចំកិច្ចប្រជុំខែតុលា ចំនួន០២លើក អ្នកចូលរួមចំនួន៤៤នាក់ ស្រី២៩នាក់។<br>- លេខាធិការដ្ឋានខេត្ត រៀបចំកិច្ចប្រជុំត្រីមាសទី៣ អ្នកចូលរួមចំនួន៤៥នាក់ ស្រី៣០នាក់។ |
| ខេត្តតាកែវ | - លោកស្រី អភិបាលរងខេត្ត ចូលរួមសហការវគ្គបណ្តុះបណ្តាលស្តីពី បែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប នៅសាលប្រជុំសាលាខេត្ត(ទីចាត់ការផែនការ និងវិនិយោគខេត្ត)។ |
| ខេត្តឧត្តរមានជ័យ | - រៀបចំកិច្ចប្រជុំស្តីពីធ្វើផែនឆ្នាំ២០១៨ របស់គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្ត អ្នកចូលរួមចំនួន៣៥នាក់ ស្រី១៧នាក់ ។ |
| ខេត្តកំពង់ឆ្នាំង | - រៀបចំកិច្ចប្រជុំប្រចាំខែតុលា អ្នកចូលរួមចំនួន១២នាក់ ស្រី៥នាក់។ |